រដ្ឋសភា
ចូល
លេខ.......................
ថ្ងៃទី...../.....ឆ្នាំ២០១.....ម៉ោង.....
បញ្ជូនទៅ.......................

# ព្រះរាជក្រម

នស/រកម/០៨១៤/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការធានារ៉ាប់រង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការធានារ៉ាប់រង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានានូវៈ

-ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង

-ផលប្រយោជន៍សាធារណៈ និងទំនុកចិត្តដល់សេវាធានារ៉ាប់រង

-សង្គតិភាពជាមួយនឹងគោលការណ៍គ្រឹះធានារ៉ាប់រងអន្តរជាតិ

-ផលប្រយោជន៍របស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាអ្នកត្រូវបានធានារ៉ាប់រង ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅៈ

-ពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រង

-កំណត់អំពីការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការធ្វើអាជីវកម្មធានារ៉ាប់រង

-ជំរុញការប្រកួតប្រជែង ភាពស្មោះត្រង់ និងតម្លាភាពក្នុងវិស័យធានារ៉ាប់រង ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដូចមានចែងក្នុងជំពូកទី ១២ នៃច្បាប់នេះ ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើនៅក្នុងច្បាប់នេះ មាននិយមន័យដូចតទៅៈ

- **ការធានារ៉ាប់រង** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះ ឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

- **ការធានារ៉ាប់រងជាកាតព្វកិច្ច** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រង ដែលអ្នកត្រូវបានធានារ៉ាប់រង ត្រូវបំពេញជាកាតព្វកិច្ចតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រងក្នុងគោលបំណងបម្រើ និងការពារផលប្រយោជន៍សាធារណៈ ។

- **កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រម

ទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង ។

- **កំណត់សំអាង** សំដៅដល់ឯកសារបណ្តោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង ជំនួសបណ្ណសន្យារ៉ាប់រងស្ថាពរ ។

- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ។

- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ។

- **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ដោយមានកំណត់ពីខ្លឹមសារសំខាន់និងចែងពីលក្ខខណ្ឌលំអិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

- **បណ្ណសន្យារ៉ាប់រងគ្រោះថ្នាក់បុគ្គល** សំដៅដល់កិច្ចសន្យាធានារ៉ាប់រងដែលផលប្រយោជន៍របស់វាជាប្រាក់ ឬផលប្រយោជន៍សំណងជាវត្ថុ ឬផលប្រយោជន៍សំណងរួមមានជាប្រាក់និងជាវត្ថុទៅឲ្យអ្នកត្រូវបានធានារ៉ាប់រងនៅពេលមានហានិភ័យកើតឡើង ដើម្បីធានាលើគ្រោះថ្នាក់ទាំងឡាយ ។

- **បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រង ។

- **ពិន័យអន្តរការណ៍** សំដៅដល់ការផាកពិន័យជាទឹកប្រាក់ចំពោះទង្វើរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលអនុវត្តផ្ទុយពីការណែនាំរបស់បញ្ញត្តិករធានារ៉ាប់រង ។

- **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង ។

- **វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដើម្បីបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងបានទិញការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ។

- **សំណងធានារ៉ាប់រង** សំដៅដល់សំណងជាប្រាក់ឬជាវត្ថុ ឬសំណងរួមជាប្រាក់និងជាវត្ថុដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រង ។

- **អភិបាលបណ្តោះអាសន្ន** សំដៅដល់អ្នកគ្រប់គ្រងបណ្តោះអាសន្ន ដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបំពេញភារកិច្ចក្រុមហ៊ុនធានារ៉ាប់រងមុនពេលធ្វើការជម្រះបញ្ជីដើម្បីវាយតម្លៃលើស្ថានភាពសាធនភាពរបស់ក្រុមហ៊ុន ។

- **អ្នកជម្រះបញ្ជី** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតុលាការ ដើម្បីធ្វើការដោះស្រាយទូទាត់បំណុលនៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវជម្រះបញ្ជី ។

- **អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង ។

- **អ្នកទទួលផល** សំដៅដល់តតិយជននៃកិច្ចសន្យា ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទង នឹងការធានារ៉ាប់រងលើអាយុជីវិតតែប៉ុណ្ណោះ ។

- **អ្នកស្នើសុំធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគត ដែលបំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ ។

- **យានយន្ត** សំដៅដល់យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីនលើផ្លូវគោក និងផ្លូវទឹក ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា ៥.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចក្នុងការចេញបទប្បញ្ញត្តិ គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើអាជីវកម្មធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៦.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចបង្កើតនិងគ្រប់គ្រងមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង ដើម្បីជំរុញការអភិវឌ្ឍ ការទ្រទ្រង់ និងការលើកកម្ពស់ការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃការធានារ៉ាប់រងដល់សាធារណជន ។

## ជំពូកទី ៣
## កិច្ចសន្យាធានារ៉ាប់រង
## ផ្នែកទី ១
## បែបបទទូទៅ

### មាត្រា ៧.-

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់រងពីហានិភ័យទាំងឡាយ ទោះបីជាប្រភេទធានារ៉ាប់រងអាយុជីវិតក្តី ឬជាប្រភេទធានារ៉ាប់រងទូទៅ

ក្តី ត្រូវតែជាការចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាបណ្ណឲ្យធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៨.-

កិច្ចសន្យាធានារ៉ាប់រង ត្រូវចែងឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ។ កិច្ចសន្យាធានារ៉ាប់រងត្រូវរៀបចំដោយយកភាសាខ្មែរជាគោល និងត្រូវមានចុះហត្ថលេខា និង/ឬផ្តិតមេដៃរបស់ភាគីទាំងសងខាង ។

## មាត្រា ៩.-

ក្នុងការធ្វើកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងត្រូវគោរពតាមគោលការណ៍ស្មោះត្រង់ ដែលមានផលប្រយោជន៍ទៅវិញទៅមក មានការស្រុះស្រួលគ្នាដោយឆ្លងតាមការចរចា និងមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈឡើយ ។

## មាត្រា ១០.-

ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចពន្យល់អ្នកត្រូវបានធានារ៉ាប់រងឲ្យបានយល់ច្បាស់អំពីលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង និងខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងដែលភ្ជាប់ជាមួយ នឹងវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗ ។

## មាត្រា ១១.-

នៅពេលដែលរូបវន្តបុគ្គល ឬនីតិបុគ្គលធ្វើសំណើសុំការធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលសំណើ ព្រមទាំងមានការឯកភាពគ្នារវាងភាគីទាំងពីរលើលក្ខខណ្ឌផ្សេងៗ នៃកិច្ចសន្យាហើយនោះ កិច្ចសន្យាធានារ៉ាប់រងអាចចាត់ទុកថាបានឯកភាពលើខ្លឹមសាររួចហើយ ។

បន្ទាប់ពីបានចុះកិច្ចសន្យារួចមក ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញបណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬចេញកំណត់សំអាង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតទៅឲ្យអ្នកស្នើសុំធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ត្រូវមានចែងនិងកំណត់ខ្លឹមសារសំខាន់ជាទូទៅដែលបានព្រមព្រៀងជាមុនរវាងភាគីទាំងពីរ ។

## មាត្រា ១២.-

វិញ្ញាបនបត្រធានារ៉ាប់រងត្រូវបញ្ជាក់អំពី៖

- គោត្តនាម និងនាម និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- បុគ្គល ឬវត្ថុដែលត្រូវបានធានារ៉ាប់រង
- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ពេលវេលាចាប់ផ្តើមនិងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និងរបៀបបង់បុព្វលាភធានារ៉ាប់រង
- របៀបនិងលក្ខខណ្ឌមួយចំនួននៃសេចក្តីប្រកាសគ្រោះថ្នាក់
- រយៈពេលនៃកិច្ចសន្យា និងរយៈពេលនៃការធានារ៉ាប់រង
- លក្ខខណ្ឌទាំងឡាយដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឲ្យគូភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់ ។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបានដោយមានការព្រមព្រៀងគ្នាជាមុន ។

## មាត្រា ១៣.-

មានតែបណ្ណសន្យារ៉ាប់រង ឬកំណត់សំអាងទេដែលកត់ត្រាការធានាទៅវិញទៅមករវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ។

សំណើសុំបន្ត ឬកែប្រែ ឬដាក់ឲ្យអនុវត្តឡើងវិញនូវកិច្ចសន្យាធានារ៉ាប់រងមួយដែលបានព្យួរទុកត្រូវបានចាត់ថាយល់ព្រម ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមិនបដិសេធនូវសំណើនោះក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ។

## មាត្រា ១៤.-

រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង ។ រាល់ការបន្ថែម ឬកែប្រែលើបណ្ណសន្យារ៉ាប់រងដើម ត្រូវធ្វើឡើងដោយកិច្ចសន្យាបន្ថែម និងត្រូវមានចុះហត្ថលេខារបស់ភាគីទាំងសងខាង ។

## មាត្រា ១៥.-

អ្នកត្រូវបានធានារ៉ាប់រង ត្រូវមានផលប្រយោជន៍ពីការធានារ៉ាប់រងដែលស្ថិតក្នុងកម្មវត្ថុដែលត្រូវបានធានារ៉ាប់រង ។

ផលប្រយោជន៍ពីការធានារ៉ាប់រង គឺជាការធ្វើសំណងដែលផ្អែកលើកម្មវត្ថុដែលត្រូវបានធានារ៉ាប់រង ។

កម្មវត្ថុដែលត្រូវបានធានារ៉ាប់រងមានទៅលើទ្រព្យសម្បត្តិ រូបរាងកាយ និងអាយុជីវិត ។

## មាត្រា ១៦.-

បន្ទាប់ពីបានធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

ការធានារ៉ាប់រងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងតាមកាលកំណត់ក្នុងកិច្ចសន្យា ។

## មាត្រា ១៧.-

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងពុំបានបង់បុព្វលាភធានារ៉ាប់រងណាមួយតាមកាលកំណត់នោះ សុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងមិនអាចព្យួរទុកឲ្យហួសពីរយៈពេល ៣០(សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងឡើយ ។ ២០(ម្ភៃ) ថ្ងៃក្រោយពីការចុះកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដោយលិខិតអនុសិដ្ឋ ឬដោយលិខិតដែលមានបញ្ជាក់ការទទួលច្បាស់លាស់ដល់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងឲ្យយកបុព្វលាភធានារ៉ាប់រងមកបង់នៅទីកន្លែងដែលបានព្រមព្រៀងគ្នា ។ ក្រោយពីបានទទួលដំណឹងរួចហើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងនៅតែមិនមកបង់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេល ១០(ដប់)ថ្ងៃ នោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិលុបកិច្ចសន្យាចោល ។

## មាត្រា ១៨.-

ការបាត់បង់ ឬការខូចខាតទាំងឡាយបណ្តាលមកពីហានិភ័យដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រង ត្រូវស្ថិតនៅក្នុងបន្ទុកធ្វើសំណងរបស់ក្រុមហ៊ុនធានារ៉ាប់រង ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើសំណងចំពោះការបាត់បង់ ឬការខូចខាតទាំងឡាយដែលបណ្តាលមកពីកំហុសដោយចេតនា ឬដោយបន្លំបោកប្រាស់របស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ។

ក្រុមហ៊ុនធានារ៉ាប់រងធានាផងដែរ ចំពោះការបាត់បង់និងការខូចខាតដែលបង្កឡើងដោយបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ទោះជាប្រភេទនិងភាពធ្ងន់ធ្ងរនៃកំហុសទាំងនោះបែបណាក៏ដោយ ។

## មាត្រា ១៩.-

កិច្ចសន្យាធានារ៉ាប់រងមួយអាចត្រូវបានលុបចោល នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញថាអ្នកត្រូវបានធានារ៉ាប់រងមានការលាក់លៀម ឬធ្វើប្រតិវេទន៍ខុសដោយចេតនា ហើយបណ្តាលឲ្យមានការផ្លាស់ប្តូរកម្មវត្ថុនៃហានិភ័យ ។

ការភ្លេចភ្លាំង ឬការធ្វើប្រតិវេទន៍មិនច្បាស់លាស់ដោយអចេតនារបស់អ្នកត្រូវបានធានារ៉ាប់រងនឹងមិននាំទៅដល់ការលុបចោលនូវការធានារ៉ាប់រងទេ ។

## មាត្រា ២០.-

ប្រសិនបើគ្រោះថ្នាក់បានបង្កើតឡើងដោយចេតនាតែបន្លំរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញភស្តុតាងច្បាស់លាស់នៃអំពើនោះ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីបដិសេធការទទួលខុសត្រូវក្នុងករណីដែលមិនទាន់បានធ្វើសំណង ឬដើម្បីទារសំណងមកវិញក្នុងករណីបានធ្វើសំណងរួចហើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២១.-**

ក្នុងប្រភេទធានារ៉ាប់រងភារៈទទួលខុសត្រូវ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានបង្កឲ្យមានការខូចខាត ឬបាត់បង់ដល់តតិយជន ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងផ្ទាល់ទៅតតិយជនដែលរងគ្រោះនោះ ។

**មាត្រា ២២.-**

ក្នុងការអនុវត្តកិច្ចសន្យាធានារ៉ាប់រង ភាគីមានសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ។

លក្ខខណ្ឌនិងនីតិវិធីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ២
## ការធានារ៉ាប់រងទូទៅ

**មាត្រា ២៣.-**

ការធានារ៉ាប់រងទូទៅ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និងសុខភាព ។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅរួមមានការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព ។

ការធានារ៉ាប់រងទ្រព្យសម្បត្តិ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើសំណងដល់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលទ្រព្យសម្បត្តិរបស់បុគ្គលនោះបានខូចខាត បាត់បង់ ឬអន្តរាយដោយសារហានិភ័យដែលត្រូវបានធានា ។ សំណងដែលត្រូវផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងទៅឲ្យអ្នកត្រូវបានធានារ៉ាប់រង មិនអាចមានតម្លៃលើសពីវត្ថុដែលបានធ្វើប្រតិវេទន៍ នៅពេលចុះកិច្ចសន្យាធានារ៉ាប់រងឡើយ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការធានារ៉ាប់រងទ្រព្យសម្បត្តិមានដូចជា អគារ នាវា ជាដើម ។

ការធានារ៉ាប់រងភារៈទទួលខុសត្រូវ ជាកិច្ចសន្យាធានារ៉ាប់រងលើទឹកប្រាក់សំណងដែលអ្នកត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចបង់ឲ្យតតិយជនដែលទទួលរងរបួសលើរូបរាងកាយ ឬអាយុជីវិត ឬទទួលរងការខូចខាតលើទ្រព្យសម្បត្តិ ដោយសារទង្វើរបស់អ្នកត្រូវបានធានារ៉ាប់រង ឬសកម្មភាពដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ។ ប្រភេទផលិតផលធានារ៉ាប់រងភារៈទទួលខុសត្រូវរួមមាន ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ ។

ការធានារ៉ាប់រងសុខភាព ជាកិច្ចសន្យាធានារ៉ាប់រងលើការចំណាយសម្រាប់ការព្យាបាលរបួស ជំងឺ និងការចំណាយផ្សេងៗ ដូចជាការចំណាយសម្រាប់ការថែរក្សាអ្នកជំងឺក្នុងរយៈពេលវែងជាដើម ដល់អ្នកត្រូវបានធានារ៉ាប់រងដែលទទួលរងគ្រោះបណ្តាលមកពីគ្រោះថ្នាក់ទាំងឡាយដល់រូបរាងកាយ ឬជំងឺផ្សេងៗ ។

## មាត្រា ២៤.-

ករណីមានការបាត់បង់ទាំងស្រុងនូវកម្មវត្ថុដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពីហេតុការណ៍ណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងបណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយស្របច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០(កៅសិប) ភាគរយនៃបុព្វលាភធានារ៉ាប់រងចំពោះរយៈពេលដែលនៅសល់ ។

## មាត្រា ២៥.-

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ក្នុងការប្តឹងតទល់ជាមួយនឹងតតិយជនដែលបានបង្កឲ្យមានការខូចខាតដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងទាមទារសំណងពីបច្ចាញាតិ បុព្វញាតិ ញាតិពន្ធ អ្នកគ្រប់គ្រង និងកម្មករ និយោជិតដែលរស់នៅជម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទេ លើកលែងតែករណីដែលមានភស្តុតាងបញ្ជាក់ថា មានការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយចេតនាដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ ។

# ផ្នែកទី ៣
# ការធានារ៉ាប់រងអាយុជីវិត

## មាត្រា ២៦.-

ការធានារ៉ាប់រងអាយុជីវិត ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាទៅលើការស្លាប់ ឬការរស់រានមានជីវិតដោយអាចរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជំងឺធ្ងន់ធ្ងរ ឬជំងឺទូទៅ ។ ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតមានការធានារ៉ាប់រងមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល ការធានារ៉ាប់រងទាយជ្ជទាន ការធានារ៉ាប់រងធនលាភ ។

ការធានារ៉ាប់រងមានកាលកំណត់ ជាការធានារ៉ាប់រងអាយុជីវិតនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រង បានស្លាប់នៅក្នុងរយៈពេលដែលបានកំណត់ជាក់លាក់ណាមួយ ដូចជា ៥(ប្រាំ)ឆ្នាំ ឬ១០ (ដប់) ឆ្នាំ ឬស្លាប់នៅមុនអាយុដែលបានកំណត់ទុកដោយផ្តល់ផលប្រយោជន៍ទៅឲ្យអ្នកទទួលផលដូចបានកំណត់ក្នុងកិច្ចសន្យានោះ ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិតបន្ទាប់ពីរយៈពេលដែលបាន កំណត់ទុកក្នុងកិច្ចសន្យានោះអ្នកទទួលផលពុំអាចទទួលផលប្រយោជន៍ពីការធានារ៉ាប់រងនេះឡើយ ។

ការធានារ៉ាប់រងមួយជីវិតកាល ជាកិច្ចសន្យាធានារ៉ាប់រងដែលធានាលើការស្លាប់របស់អ្នកត្រូវបានធានារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រងអាចត្រូវបានបង់សម្រាប់រយៈពេលច្បាស់លាស់ ឬមួយជីវិត ។ ក្នុងការធានារ៉ាប់រងមួយជីវិតកាល គេអាចកំណត់ចំនួនបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ក្នុងចំនួនស្មើគ្នា ដោយរៀងរាល់ឆ្នាំ ក្នុងអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិត ។ ក្រុមហ៊ុនធានារ៉ាប់រង

ត្រូវផ្តល់ ផលប្រយោជន៍ទៅឲ្យក្រុមគ្រួសាររបស់អ្នកស្លាប់ ឬទៅឲ្យអ្នកទទួលផលណាម្នាក់ដែលមានសិទ្ធិទទួល នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាព ។

ការធានារ៉ាប់រងទាយជ្ជទាន ជាការធានារ៉ាប់រងអាយុជីវិតដែលផលប្រយោជន៍បានមកពីការធានារ៉ាប់រងអាចត្រូវផ្តល់ទៅឲ្យអ្នកត្រូវបានធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនោះនៅរស់រានមានជីវិតក្នុងអំឡុងពេលដែលត្រូវបានធានាដូចបានកំណត់ក្នុងកិច្ចសន្យា ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់មុនកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យានោះ ផលប្រយោជន៍ត្រូវផ្តល់ទៅឲ្យអ្នកទទួលផលវិញ ។

ការធានារ៉ាប់រងធនលាភ ជាកិច្ចសន្យាធានារ៉ាប់រងដែលផ្តល់ប្រាក់ចំណូលដល់អ្នកត្រូវបានធានារ៉ាប់រងសម្រាប់អាយុកាលចូលនិវត្តន៍ ។

## មាត្រា ២៧.-

ចំពោះការធានារ៉ាប់រងអាយុជីវិត ក្រោយពីបានធ្វើសំណងរួចហើយ ក្រុមហ៊ុនធានារ៉ាប់រងមិនអាចទាមទារការផ្ទេរសិទ្ធិពីភាគីជាប់កិច្ចសន្យា ឬពីអ្នកទទួលផលដើម្បីប្តឹងតទល់នឹងតតិយជនឡើយ ។

## មាត្រា ២៨.-

បុគ្គលម្នាក់ៗអាចស្នើសុំការធានារ៉ាប់រងអាយុជីវិតរបស់ខ្លួន ឬរបស់តតិយជន កាលបើតតិយជននោះបានយល់ព្រមជាលាយលក្ខណ៍អក្សរបញ្ជាក់ច្បាស់ពីទឹកប្រាក់ត្រូវបានធានារ៉ាប់រង ។

ការធានារ៉ាប់រងអាយុជីវិត ត្រូវបានហាមឃាត់ចំពោះ៖

១ - ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ។

២ - ជនដែលកំពុងព្យាបាលជំងឺវិកលចរិត ។

## មាត្រា ២៩.-

ក្រៅពីនិទ្ទេសចាំបាច់ក្នុងកិច្ចសន្យាធានារ៉ាប់រង បណ្ណសន្យារ៉ាប់រងអាយុជីវិតត្រូវបញ្ជាក់ដូចខាងក្រោម៖

១ - គោត្តនាម នាម និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកដែលត្រូវចុះកិច្ចសន្យា ។

២ - គោត្តនាម និងនាមរបស់អ្នកទទួលផល ប្រសិនបើមាន ។

៣ - ហេតុការណ៍ ឬការកំណត់ដែលត្រូវប្រគល់ឲ្យវិញនូវទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង ។

៤ - លក្ខខណ្ឌនៃការបន្ធូរបន្ថយ ប្រសិនបើមានកំណត់ក្នុងកិច្ចសន្យា ។

## មាត្រា ៣០.-

អ្នកទទួលផលមិនអាចទទួលផលប្រយោជន៍ពីការធានារ៉ាប់រងអាយុជីវិតបានទេ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ។

**មាត្រា ៣១.-**

អ្នកទទួលផលមិនអាចទទួលផលប្រយោជន៍ពីការធានារ៉ាប់រងអាយុជីវិតបានទេ ប្រសិនបើអ្នកទទួលផលនោះជាចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងការប្រព្រឹត្តបទឃាតកម្មទៅលើអ្នកត្រូវបានធានារ៉ាប់រង ។

## ផ្នែកទី ៤
## ការធានារ៉ាប់រងបន្ត

**មាត្រា ៣២.-**

ការធានារ៉ាប់រងបន្ត ជាកិច្ចប្រតិបត្តិការធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀត ដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្តនូវហានិភ័យមួយផ្នែក ឬទាំងស្រុងដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង ។

ក្នុងករណីធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមនៅតែទទួលខុសត្រូវដដែលចំពោះអ្នកត្រូវបានធានារ៉ាប់រង ។

## ជំពូកទី ៤
## ប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច
## ផ្នែកទី ១
## ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត

**មាត្រា ៣៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលជាម្ចាស់យានយន្ត ដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវ ចំពោះរាល់ការខូចខាតបង្កឡើងដល់តតិយជនដែលបណ្ដាលមកពីសកម្មភាពនៃយានយន្តរបស់ខ្លួនរួមទាំងរ៉ឺម៉កសណ្ដោងគ្រប់ប្រភេទ ។

ការធានារ៉ាប់រងនេះមិនត្រឹមតែមានប្រសិទ្ធភាពចំពោះម្ចាស់យានយន្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានប្រសិទ្ធភាពផងដែរចំពោះអ្នកបើកបរនិងអ្នកកាន់កាប់ថែទាំយានយន្ត ។

ប្រភេទយានយន្តប្រកបអាជីវកម្មទាំងឡាយដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៤.-**

ប្រភេទយានយន្តផ្សេងទៀតដែលតម្រូវឲ្យមានការធានារ៉ាប់រងជាកាតព្វកិច្ច ក្រៅពីយានយន្តដែលមានកំណត់នៅក្នុងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ព្រះបរមរាជវាំង

ROYAUME DU CAMBODGE

LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៥.-**

ចំពោះតតិយជនទាំងឡាយដែលបានទទួលរងគ្រោះដល់រូបរាងកាយ និង/ឬមរណភាពដោយសារយានយន្តដែលមានការធានារ៉ាប់រងបង្កឡើង ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើសំណងចំពោះរាល់ការខូចខាតអន្តរាយនោះឲ្យបានទាន់ពេលវេលាដែល និងសមស្របតាមកម្រិតនៃការខូចខាត ។

**មាត្រា ៣៦.-**

ការធានារ៉ាប់រងនេះ គ្របដណ្តប់យ៉ាងតិច ចំពោះជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរដែលបានទទួលរងរបួសពិការ ឬមរណភាព ទោះបីជនទាំងនោះត្រូវបានដឹកជញ្ជូនក្នុងយានយន្តដែលត្រូវបានធានារ៉ាប់រងក៏ដោយ ។

## ផ្នែកទី ២
## ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

**មាត្រា ៣៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលជាម្ចាស់ការដ្ឋាន ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ។

នៅពេលបើកការដ្ឋាន បុគ្គលជាម្ចាស់ការដ្ឋានត្រូវមានភស្តុតាងបញ្ជាក់ថា ខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ។

ប្រភេទការដ្ឋានដែលត្រូវមានការធានារ៉ាប់រង ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ៣
## ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ

**មាត្រា ៣៨.-**

រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូននានា ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបាយដឹកជញ្ជូនរបស់ខ្លួនទោះបីជាមធ្យោបាយដឹកជញ្ជូនទាំងនោះចរាចរតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ឬផ្លូវដែកក៏ដោយ ។

ប្រភេទមធ្យោបាយដឹកជញ្ជូនអ្នកដំណើរដែលត្រូវមានការធានារ៉ាប់រង ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥
# ការធានារ៉ាប់រងខ្នាតតូច

**មាត្រា ៣៩.-**

ការធានារ៉ាប់រងខ្នាតតូច ជាការផ្តល់កិច្ចសន្យាធានារ៉ាប់រងដល់ប្រជាពលរដ្ឋដែលមានចំណូលទាប ដូចជាការធានារ៉ាប់រងខ្នាតតូចលើទ្រព្យសម្បត្តិ ការធានារ៉ាប់រងខ្នាតតូចលើអាយុជីវិត ការធានារ៉ាប់រងខ្នាតតូចលើរូបរាងកាយ ។

**មាត្រា ៤០.-**

ការធានារ៉ាប់រងខ្នាតតូច ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៦
# គ្រឹះស្ថានធានារ៉ាប់រងនិងការផ្តល់អាជ្ញាបណ្ណ
## ផ្នែកទី ១
## ក្រុមហ៊ុនធានារ៉ាប់រង

**មាត្រា ៤១.-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ទោះបីជារបស់រដ្ឋក្តី ជារបស់ឯកជនក្តី ឬជាក្រុមហ៊ុនចម្រុះក្តីអាចត្រូវអនុញ្ញាតឲ្យធ្វើប្រតិបត្តិការធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជាតែក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប៉ុណ្ណោះ ។

**មាត្រា ៤២.-**

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច អាចផ្ទេរការធានារ៉ាប់រងរបស់ខ្លួនមួយផ្នែក ឬទាំងស្រុងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងបន្តបាន ។

ក្រុមហ៊ុនធានារ៉ាប់រងបន្តអាចផ្ទេរការធានារ៉ាប់រងបន្តមួយផ្នែក ឬទាំងស្រុងរបស់ខ្លួន ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងបន្តផ្សេងទៀតបាន ។

**មាត្រា ៤៣.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចស្នើសុំអាជ្ញាបណ្ណធានារ៉ាប់រងណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើអាជីវកម្មធានារ៉ាប់រងដូចខាងក្រោម៖

១- អាជីវកម្មធានារ៉ាប់រងអាយុជីវិត ។

២- អាជីវកម្មធានារ៉ាប់រងទូទៅ ។

៣- អាជីវកម្មធានារ៉ាប់រងបន្ត ។

ឃ- អាជីវកម្មធានារ៉ាប់រងខ្នាតតូច ។

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អាចធ្វើអាជីវកម្មធានារ៉ាប់រងសុខភាព និងអាជីវកម្មធានារ៉ាប់រងខ្នាតតូចបាន ។

**មាត្រា ៤៤.-**

ដើមទុនអប្បបរមាដែលតម្រូវសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវកំណត់ដោយអនុក្រឹត្យ ។ ប៉ុន្តែដើមទុនអប្បបរមាត្រូវជាប្រាក់រៀល មិនត្រូវស្ថិតក្រោមកម្រិតសមមូលនឹង ៥ ០០០ ០០០(ប្រាំលាន) អេសឌីអ័រ តាមអត្រាពេលចេញអាជ្ញាបណ្ណ ។

ចំពោះដើមទុនអប្បបរមាសម្រាប់អាជីវកម្មធានារ៉ាប់រងខ្នាតតូច ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៥.-**

ក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្រគល់អំណាចដឹកនាំ ចាត់ចែង ទូទាត់ឲ្យដល់បុគ្គលទាំងឡាយណាដែលធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬបទឧក្រិដ្ឋឡើយ ។

## ផ្នែកទី ២
## ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង

**មាត្រា ៤៦.-**

ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួសមុខឲ្យក្រុមហ៊ុនធានារ៉ាប់រង ធ្វើការណែនាំអំពីការលក់បណ្ណសន្យារ៉ាប់រង ការរៀបចំកិច្ចសន្យាធានារ៉ាប់រង ការប្រមូលបុព្វលាភ ការរៀបចំការធ្វើសំណងជាដើម ក្នុងក្របខ័ណ្ឌកំណត់ច្បាស់លាស់នៃកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងនោះ។

ជើងសាធានារ៉ាប់រងជានីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្តល់ជាសេវាប្រឹក្សា ផ្តល់ព័ត៌មានទាក់ទងនឹងប្រភេទធានារ៉ាប់រង លក្ខខណ្ឌ និងបុព្វលាភនៃកិច្ចសន្យាធានារ៉ាប់រង ធ្វើការចរចានិងរៀបចំកិច្ចសន្យាធានារ៉ាប់រងរវាងអ្នកស្នើសុំការធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង និងលក់បណ្ណសន្យារ៉ាប់រងដោយទទួលពីក្រុមហ៊ុនធានារ៉ាប់រងនូវកម្រៃជើងសាស្របច្បាប់ ។

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ជានីតិបុគ្គលឯករាជ្យដែលមានភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់វាយតម្លៃលើការខូចខាត នៅពេលដែលមានហានិភ័យធានារ៉ាប់រងកើតឡើង និងសម្រេចចេញនូវឯកសារស្តីពីការវាយតម្លៃការខូចខាត សម្រាប់ជាមូលដ្ឋានឲ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយសំណង ។ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលត្រួតពិនិត្យពីក្រុមហ៊ុនធានារ៉ាប់រងតាមកិច្ចព្រមព្រៀង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៣
## ការផ្ដល់អាជ្ញាបណ្ណធានារ៉ាប់រង

### មាត្រា ៤៧.-

គ្រឹះស្ថានធានារ៉ាប់រងដែលធ្វើអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានអាជ្ញាបណ្ណធានារ៉ាប់រងដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការសម្រេចឬបដិសេធសំណើសុំអាជ្ញាបណ្ណធានារ៉ាប់រងក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់ ។

### មាត្រា ៤៨.-

នីតិវិធីនិងលក្ខខណ្ឌនៃការផ្ដល់អាជ្ញាបណ្ណធានារ៉ាប់រង ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ៤
## របាយការណ៍ហិរញ្ញវត្ថុ

### មាត្រា ៤៩.-

ក្នុងអំឡុងពេល ៣(បី)ខែ ក្រោយពេលបញ្ចប់ឆ្នាំហិរញ្ញវត្ថុ ឬក្នុងអំឡុងពេលបន្ថែមណាមួយដែលបានទទួលការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ដល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានត្រួតពិនិត្យរួចហើយដោយសវនករប្រតិស្រុត ។ របាយការណ៍នោះត្រូវស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំខាងលើនៅក្នុងទម្រង់សង្ខេបមួយតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

### មាត្រា ៥០.-

គ្រឹះស្ថានធានារ៉ាប់រង ត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុនិងឯកសារផ្សេងៗតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## អធិការកិច្ចធានារ៉ាប់រង

### មាត្រា ៥១.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចធានារ៉ាប់រង ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចធានារ៉ាប់រង មានសិទ្ធិធ្វើអធិការកិច្ចលើក្រុមហ៊ុនធានារ៉ាប់រង និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មន្ត្រីអធិការកិច្ចធានារ៉ាប់រងមានសិទ្ធិតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវ និងស៊ើបអង្កេតបទល្មើសក្នុងវិស័យធានារ៉ាប់រង ។

## មាត្រា ៥២.-

មន្ត្រីអធិការកិច្ចធានារ៉ាប់រង ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះដោយអនុវត្តឲ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## មាត្រា ៥៣.-

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទង នឹងការពិនិត្យនិងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចធានារ៉ាប់រងមានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាងកោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។ ក្នុងករណីចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចធានារ៉ាប់រងត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រងក្នុងការពិនិត្យស៊ើបអង្កេតបទល្មើស និងការឃាត់ខ្លួនជនសង្ស័យ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

មន្ត្រីអធិការកិច្ចធានារ៉ាប់រង មានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

## មាត្រា ៥៤.-

នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសម្គាល់និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៥៥.-

នៅក្នុងដំណើរការអធិការកិច្ចធានារ៉ាប់រង ក្នុងករណីមានភស្តុតាង ឬលទ្ធផលវិភាគផ្ទៀងផ្ទាត់បញ្ជាក់ថា មានការលក់ផលិតផលធានារ៉ាប់រងដែលផ្ទុយពីការអះអាងនៅពេលស្នើសុំអាជ្ញាប័ណ្ណ មន្ត្រី

អធិការកិច្ចធានារ៉ាប់រងមានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្នមិនឲ្យលក់ផលិតផលទាំងនោះ ដើម្បីដោះស្រាយតាមនីតិវិធី ។

**មាត្រា ៥៦.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង អាចប្តឹងតវ៉ាក្នុងរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ២(ពីរ)ខែ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង ។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជននោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី ។

**មាត្រា ៥៧.-**

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥៨.-**

មន្ត្រីអធិការកិច្ចធានារ៉ាប់រង ដែលបំពេញមុខងារ និងភារកិច្ចប្រកបដោយសុចរិតភាព ត្រូវបានការពារដោយច្បាប់ ។

## ជំពូកទី ៨
## ការជម្រះបញ្ជីរំលាយក្រុមហ៊ុន
### ផ្នែកទី ១
### ការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត

**មាត្រា ៥៩.-**

ក្រុមហ៊ុនធានារ៉ាប់រងមួយ អាចដំណើរការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តបាន លុះត្រាតែក្រុមហ៊ុននោះមានស្ថានភាពសាធនភាពគ្រប់គ្រាន់ ។

**មាត្រា ៦០.-**

ក្រុមហ៊ុនធានារ៉ាប់រងមួយដែលមានស្ថានភាពសាធនភាពគ្រប់គ្រាន់ អាចស្នើសុំជម្រះបញ្ជីដោយស្ម័គ្រចិត្តបាន ក្នុងករណីណាមួយដូចខាងក្រោម៖

ក-ការដល់អាយុកាលរបស់ក្រុមហ៊ុន ។

ខ-សេចក្តីសម្រេចរបស់មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញរបស់ម្ចាស់ហ៊ុន ដោយអនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន ។

**មាត្រា ៦១.-**

អភិបាលក្រុមហ៊ុន ឬម្ចាស់ហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោតនៅពេលមហាសន្និបាតម្ចាស់ហ៊ុន អាចស្នើឲ្យមានការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

**មាត្រា ៦២.-**

លិខិតកោះអញ្ជើញស្តីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងគោលបំណងជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីរំលាយក្រុមហ៊ុននោះ ។

**មាត្រា ៦៣.-**

ក្រោយពីទទួលបានសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុនស្តីពីការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៦៤.-**

ក្រោយពីទទួលបានពាក្យស្នើសុំជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តរួចមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញវិញ្ញាបនបត្រអនុញ្ញាតឲ្យជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តជូនក្រុមហ៊ុនសាមី បន្ទាប់ពីបានពិនិត្យឃើញថាមានមូលហេតុសមស្រប ។

**មាត្រា ៦៥.-**

បន្ទាប់ពីបានទទួលវិញ្ញាបនបត្រអនុញ្ញាតនោះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបញ្ឈប់ការចុះកិច្ចសន្យាធានារ៉ាប់រងថ្មី និងត្រូវផ្ទេរបណ្ណសន្យារ៉ាប់រងដែលមានស្រាប់ទៅឲ្យក្រុមហ៊ុនផ្សេងទៀត ឲ្យបានមុនការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

**មាត្រា ៦៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតែងតាំងអ្នកជម្រះបញ្ជីដែលមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិនៅក្នុងបញ្ជីប្រតិស្រុតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៦៧.-**

សិទ្ធិអំណាចនិងភារកិច្ចរបស់អ្នកជម្រះបញ្ជីមានដូចខាងក្រោម៖

-ធ្វើជាតំណាងពេញច្បាប់ឲ្យក្រុមហ៊ុនក្នុងការដឹកនាំនិងគ្រប់គ្រងបន្តដោយផ្តាច់មុខរហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់

-រៀបចំឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធានាឲ្យមានស្ថានភាពពិតនៃគណនីពាក់ព័ន្ធនីមួយៗ ធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការជម្រះបញ្ជីនោះ

-ផ្ទៀងផ្ទាត់ឡើងវិញនូវអត្ថិភាពចលនទ្រព្យនិងអចលនទ្រព្យតាមបញ្ជីសារពើភណ្ឌ និងចាត់វិធានការថែរក្សាទ្រព្យសម្បត្តិទាំងនោះឲ្យបានគង់វង្សដើម្បីធានាសមភាពឲ្យម្ចាស់ភាគហ៊ុននិងម្ចាស់បំណុល

-ចេញសេចក្តីប្រកាសជូនដំណឹងជាសាធារណៈពីការជម្រះបញ្ជីក្រុមហ៊ុន ដោយដាក់ឱសានវាទឲ្យម្ចាស់បំណុលម្នាក់ៗផ្តល់ឯកសារសំណាងនៃឥណទេយ្យរបស់ខ្លួន ហើយប្រសិនបើម្ចាស់បំណុលណាមិនបានផ្តល់ទាន់ពេលកំណត់នោះ សាមីជនត្រូវថ្លោះសិទ្ធិទាមទារបំណុលពីអ្នកជម្រះបញ្ជី

-កោះប្រជុំម្ចាស់ភាគហ៊ុនទាំងអស់និងបុគ្គលដែលពាក់ព័ន្ធ ក្នុងករណីមានការសម្រេចទទួលយកនិងធ្វើអាជីវកម្មបន្តនូវក្រុមហ៊ុនជាកម្មវត្ថុនៃការជម្រះបញ្ជី ដើម្បីឲ្យធ្វើសេចក្តីសម្រេចឯកភាពគ្នាជាគោលការណ៍ពីកិច្ចការនោះ

-ចេញសេចក្តីប្រកាសបដិសេធចំពោះកិច្ចព្រមព្រៀង ឬលិខិតស្នាមទាំងឡាយណាដែលក្រុមហ៊ុនបានធ្វើឡើងដោយមិនប្រក្រតី ឬមិនស្របច្បាប់ នៅមុនពេលចាប់ផ្តើមនីតិវិធីនៃការជម្រះបញ្ជី

-រៀបចំបញ្ជីរាយនាមកូនបំណុលទាំងអស់ជាមួយនឹងទឹកប្រាក់ដែលនៅជំពាក់ក្រុមហ៊ុនដោយរាប់បញ្ចូលទាំងម្ចាស់ហ៊ុនផងដែរប្រសិនបើមាន ហើយតឹងទារបំណុលទាំងនោះតាមគ្រប់វិធីទោះមិនទាន់ដល់កាលកំណត់ក្តី

-រៀបចំបញ្ជីរាយនាមម្ចាស់បំណុលទាំងអស់ដែលត្រូវបានទទួលស្គាល់ជាមួយនឹងទឹកប្រាក់ដែលត្រូវទូទាត់សង ដោយរាប់បញ្ចូលទាំងប្រាក់ពន្ធដារដែលនៅជំពាក់រដ្ឋ និងប្រាក់បៀវត្សរ៍របស់កម្មករនិយោជិតតាមច្បាប់ជាធរមាន

-ជម្រះទ្រព្យសកម្មរបស់ក្រុមហ៊ុនតាមការលក់ចេញឬតាមគ្រប់វិធីផ្សេងទៀត

-ជម្រះទ្រព្យអកម្មរបស់ក្រុមហ៊ុនតាមការទូទាត់សងបំណុលទៅតាមលទ្ធភាពជាក់ស្តែង ដោយអនុវត្តតាមអាទិភាព ដូចមានចែងនៅក្នុងមាត្រា ៨៦ នៃច្បាប់នេះ

-រៀបចំតារាងតុល្យការនៃការជម្រះបញ្ជី បែងចែកទឹកប្រាក់ជាលទ្ធផលនៃការជម្រះបញ្ជីឲ្យម្ចាស់ភាគហ៊ុន និងជម្រះគណនីពាក់ព័ន្ធទាំងអស់ទុកជាការបញ្ចប់ការជម្រះបញ្ជីជាស្ថាពរ ។

សិទ្ធិអំណាច និងភារកិច្ចរបស់អ្នកជម្រះបញ្ជីត្រូវស្ថិតនៅក្រោមការតាមដាន និងការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិចេញប្រកាសស្តីពីការបំពេញបន្ថែមសិទ្ធិអំណាចនិងភារកិច្ចរបស់អ្នកជម្រះបញ្ជី ។

**មាត្រា ៦៨.-**

ការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តអ្នកជម្រះបញ្ជីត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ចុះផ្សាយលិខិតជូនដំណឹងស្តីពីការរំលាយក្រុមហ៊ុនជាបន្ទាន់សម្រាប់រយៈពេល ២(ពីរ) សប្តាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយឬចែកចាយនៅក្នុងកន្លែងដែលក្រុមហ៊ុនមានទីស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀតដូចកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-កោះប្រជុំជាមួយម្ចាស់ហ៊ុន កូនបំណុល និងម្ចាស់បំណុលដោយឡែក ឬរួមគ្នាតាមការចាំបាច់

-នៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ យ៉ាងយូរបំផុតគិតពីថ្ងៃបញ្ចប់កិច្ចប្រជុំចុងក្រោយខាងលើ អ្នកជម្រះបញ្ជីត្រូវធ្វើរបាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយភ្ជាប់មកជាមួយនូវកំណត់ហេតុនៃអង្គប្រជុំទាំងនោះ បញ្ជីរាយនាមនៃកូនបំណុល បញ្ជីរាយនាមនៃម្ចាស់បំណុលដែលមានការទទួលស្គាល់ និងបញ្ជីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនជាកម្មវត្ថុនៃការជម្រះបញ្ជីនោះ ។

បន្ទាប់ពីទទួលបានសេចក្តីសម្រេចឯកភាពនេះពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួច ទើបអ្នកជម្រះបញ្ជីអាចអនុវត្តភារកិច្ចរបស់ខ្លួនរហូតដល់ចប់ទាំងស្រុង ។

-នៅក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ យ៉ាងយូរបំផុតគិតពីថ្ងៃបញ្ចប់ការជម្រះបញ្ជី អ្នកជម្រះបញ្ជីត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីលទ្ធផលនៃការជម្រះបញ្ជី និងសេចក្តីប្រកាសពីការបញ្ចប់ការជម្រះបញ្ជីនោះជាស្ថាពរ ។

## មាត្រា ៦៩.-

បន្ទាប់ពីទទួលបានសេចក្តីប្រកាសស្តីពីការបញ្ចប់ការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដកហូតអាជ្ញាបណ្ណជានាប់រងក្នុងរយៈពេល ៣(បី)ខែ យ៉ាងយូរ ។

## មាត្រា ៧០.-

ក្រោយពេលដែលការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តត្រូវបានបញ្ចប់ អភិបាលក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីការរំលាយក្រុមហ៊ុនទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីប្រកាសពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបញ្ចប់អត្ថិភាពគតិយុត្តរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

## មាត្រា ៧១.-

នៅក្នុងរយៈពេលនៃការជម្រះបញ្ជីដោយស្ម័គ្រចិត្តរបស់ក្រុមហ៊ុន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធអាចស្នើសុំទៅតុលាការ ដើម្បីឲ្យដាក់ការជម្រះបញ្ជីក្រុមហ៊ុនដោយស្ម័គ្រចិត្តក្រោមការត្រួតពិនិត្យរបស់តុលាការ ។

## មាត្រា ៧២._

ប្រសិនបើសកម្មភាពរបស់អ្នកជម្រះបញ្ជីត្រូវបានរារាំង ឬបង្អាក់ដោយក្រុមហ៊ុនធានារ៉ាប់រងអ្នកជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តអាចប្រើប្រាស់សិទ្ធិប្តឹងតវ៉ាទៅតុលាការបន្ទាប់ពីបានរាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# ផ្នែកទី ២
# កិច្ចអភិបាលបណ្ដោះអាសន្ន

## មាត្រា ៧៣._

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមួយមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិតែងតាំងអភិបាលបណ្ដោះអាសន្នមួយរូប សម្រាប់រយៈពេលមិនលើសពី ៣(បី)ខែ ដំបូង ដើម្បីស្ដារក្រុមហ៊ុនឡើងវិញ ។

ប្រសិនបើចាំបាច់ អាណត្តិរបស់អភិបាលបណ្ដោះអាសន្នអាចត្រូវបានពន្យារពេល ៣(បី)ខែ បន្ថែមទៀត ។

## មាត្រា ៧៤._

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងអភិបាលបណ្ដោះអាសន្នដែលមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិនៅក្នុងបញ្ជីប្រតិស្រុតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ៧៥._

អភិបាលបណ្ដោះអាសន្នមានសិទ្ធិគ្រប់គ្រង និងដឹកនាំការងាររបស់ក្រុមហ៊ុនធានារ៉ាប់រងនោះ ។ តួនាទីសំខាន់របស់អភិបាលបណ្ដោះអាសន្នរួមមាន ការវាយតម្លៃសាធនភាពរបស់ក្រុមហ៊ុន និងចាត់វិធានការប្រុងប្រយ័ត្នដើម្បីស្ដារស្ថានភាពក្រុមហ៊ុនឡើងវិញ និងការពារផលប្រយោជន៍សាធារណជន។

## មាត្រា ៧៦._

ក្នុងដំណាក់កាលនៃកិច្ចអភិបាលបណ្ដោះអាសន្ន បទប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី ៤ អានុភាពនៃការបើកសំណុំរឿងក្ស័យធននៃច្បាប់ស្ដីពីក្ស័យធន ត្រូវយកមកអនុវត្តផងដែរ ។

## មាត្រា ៧៧._

ប្រសិនបើការវាយតម្លៃបង្ហាញថាក្រុមហ៊ុនធានារ៉ាប់រងនោះអាចមានសាធនភាពគ្រប់គ្រាន់ និងអាចអនុវត្តតាមច្បាប់និងរាល់វិធានការប្រុងប្រយ័ត្ន អភិបាលបណ្ដោះអាសន្នត្រូវធ្វើរបាយការណ៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលុបចោលវិធានការប្រុងប្រយ័ត្នទាំងឡាយដែលបានដាក់ចេញទល់នឹងក្រុមហ៊ុននេះ ហើយកិច្ចអភិបាលបណ្ដោះអាសន្នត្រូវបានបញ្ចប់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៨.-**

ប្រសិនបើការវាយតម្លៃបង្ហាញថា ក្រុមហ៊ុនជានាវ៉ាប់រងនោះអាចមានសាធនភាពគ្រប់គ្រាន់ ប៉ុន្តែមិនអាចអនុវត្តតាមច្បាប់ និងរាល់វិធានការប្រុងប្រយ័ត្នក្នុងរយៈពេល ៣(បី)ខែ បានទេក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវដកហូតអាជ្ញាបណ្ណរបស់ក្រុមហ៊ុនជាបណ្តោះអាសន្ន ហើយកិច្ចអភិបាលបណ្តោះអាសន្នត្រូវប្តូរទៅជាការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

នីតិវិធីនៃការជម្រះបញ្ជីដោយស្ម័គ្រចិត្ត ត្រូវគោរពតាមនីតិវិធីដែលមានចែងក្នុងផ្នែកទី ១ នៃជំពូកនេះ ។

**មាត្រា ៧៩.-**

ប្រសិនបើការវាយតម្លៃបង្ហាញថាក្រុមហ៊ុនធានារ៉ាប់រងស្ថិតក្នុងអសាធនភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវដកហូតអាជ្ញាបណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុន ហើយកិច្ចអភិបាលបណ្តោះអាសន្នត្រូវប្តូរទៅជាការជម្រះបញ្ជីក្រុមហ៊ុនតាមផ្លូវតុលាការ ។

**មាត្រា ៨០.-**

ប្រសិនបើសកម្មភាពរបស់អភិបាលបណ្តោះអាសន្នត្រូវបានរាំង ឬបង្អាក់ដោយក្រុមហ៊ុនធានារ៉ាប់រងអភិបាលបណ្តោះអាសន្នអាចប្រើប្រាស់សិទ្ធិប្តឹងតវ៉ាទៅតុលាការ បន្ទាប់ពីបានរាយការណ៍ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ផ្នែកទី ៣
## ការជម្រះបញ្ជីតាមផ្លូវតុលាការ

**មាត្រា ៨១.-**

អនុលោមតាមមាត្រា ៧៩ ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ពាក្យប្តឹងទៅតុលាការដើម្បីចាប់ផ្តើមនីតិវិធីជម្រះបញ្ជីតាមផ្លូវតុលាការ ។

**មាត្រា ៨២.-**

តុលាការត្រូវជ្រើសរើសអ្នកជម្រះបញ្ជីដែលមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិនៅក្នុងបញ្ជីប្រតិស្រុតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អភិបាលបណ្តោះអាសន្នក៏អាចត្រូវបានជ្រើសរើសជាអ្នកជម្រះបញ្ជីដោយតុលាការផងដែរ ។

**មាត្រា ៨៣.-**

អ្នកជម្រះបញ្ជីត្រូវជម្រះទ្រព្យសម្បត្តិ និងទូទាត់សំណងចំពោះបំណុលទាំងអស់របស់ក្រុមហ៊ុនក្រោមការត្រួតពិនិត្យរបស់តុលាការ និងដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ស្តី

LE MINISTRE DU PALAIS

អ្នកជម្រះបញ្ជីអនុវត្តតួនាទី និងសិទ្ធិអំណាចរបស់អភិបាលបណ្ដោះអាសន្ននៅក្នុងដំណាក់កាលជម្រះបញ្ជី ដែលមានកំណត់ដោយច្បាប់ស្ដីពីក្ស័យធន លើកលែងតែមានបញ្ញត្តិដោយឡែកក្នុងច្បាប់នេះ ។

**មាត្រា ៨៤.-**

ប្រសិនបើសកម្មភាពរបស់អ្នកជម្រះបញ្ជីតាមផ្លូវតុលាការត្រូវបានរារាំង ឬបង្អាក់ដោយក្រុមហ៊ុនធានារ៉ាប់រង អ្នកជម្រះបញ្ជីតាមផ្លូវតុលាការអាចប្រើប្រាស់សិទ្ធិដើម្បីប្ដឹងតវ៉ាទៅតុលាការ ។

## ផ្នែកទី ៤
## បទប្បញ្ញត្តិរួមនៃការជម្រះបញ្ជី

**មាត្រា ៨៥.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអភិបាលបណ្ដោះអាសន្ន ឬអ្នកជម្រះបញ្ជីត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ដោយត្រូវបញ្ជូនព័ត៌មានកំណត់ហេតុលិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទង នឹងបទល្មើសនោះភ្ជាប់មកជាមួយផង ប្រសិនបើពិនិត្យឃើញថាមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។

**មាត្រា ៨៦.-**

លំដាប់អាទិភាពនៃការសងបំណុលត្រូវកំណត់ដូចខាងក្រោម៖

ក-លាភការនិងសោហ៊ុយចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចអភិបាលបណ្ដោះអាសន្ន និងការជម្រះបញ្ជី ។

ខ-បណ្ដឹងទាមទាររបស់អ្នកទាមទារសំណងធានារ៉ាប់រង ។

គ-បណ្ដឹងទាមទាររបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ។

ឃ-ប្រាក់បៀវត្សរ៍បុគ្គលិកនិងកម្មករនិយោជិត សេវារដ្ឋបាល ប្រាក់ប្រដាប់ក្ដី និងពន្ធផ្សេងៗទៀតរបស់តុលាការ ។

ង-បណ្ដឹងទាមទារដែលមានកិច្ចធានា ។

ច-ពន្ធដាររបស់រដ្ឋដែលមិនបានតម្កល់លិខិតជូនដំណឹង ។

ឆ-បណ្ដឹងទាមទារគ្មានកិច្ចធានាទាំងអស់ដែលបានទទួលស្គាល់ ។

**មាត្រា ៨៧.-**

ក្នុងការជម្រះបញ្ជីក្រុមហ៊ុនធានារ៉ាប់រង ទោះបីក្រុមហ៊ុនស្ថិតក្នុងអសាធនភាពឬមានសាធនភាព ការវាយតម្លៃទ្រព្យសម្បត្តិនិងសំណងទាំងអស់ រួមបញ្ចូលទាំងសំណងនៃបណ្ណសន្យារ៉ាប់រង ត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៨៨.-**

លាភការនិងសោហ៊ុយចំណាយផ្សេងៗ សម្រាប់កិច្ចអភិបាលបណ្ដោះអាសន្ននិងការជម្រះបញ្ជី

ត្រូវគិតដោយផ្អែកលើមូលដ្ឋាននៃអត្រាតម្លៃវិជ្ជាជីវៈ និងជាបន្ទុកចំណាយដោយស្វ័យប្រវត្តិរបស់ក្រុមហ៊ុនធានារ៉ាប់រង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសសម្រាប់គ្រប់គ្រងអត្រាប្រាក់បំណាច់សម្រាប់អភិបាលបណ្ដោះអាសន្ន ។

## ជំពូកទី ៩
## ការផ្សះផ្សាវិវាទ

### មាត្រា ៨៩.-

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុន នឹងប្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ ។

### មាត្រា ៩០.-

ក្រោយពីភាគីបានដាក់វិវាទជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួច ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសាកសួរភាគីទាំងសងខាង និងព្យាយាមផ្សះផ្សាវិវាទដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលនៃការផ្សះផ្សាវិវាទ ដោយមានបញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមរបស់ភាគីលើការផ្សះផ្សាវិវាទ ។ កំណត់ហេតុផ្សះផ្សាវិវាទត្រូវចុះហត្ថលេខាដោយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីទាំងសងខាង និងត្រូវចម្លងជូនដល់គ្រប់ភាគីពាក់ព័ន្ធ ។

រាល់កិច្ចព្រមព្រៀងផ្សះផ្សាវិវាទដែលបានធ្វើឡើងនៅចំពោះមុខក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវមានអានុភាពអនុវត្តភ្លាម ។

### មាត្រា ៩១.-

ក្នុងពេលផ្សះផ្សាវិវាទ នៅពេលដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ជាក់ថា អ្នកត្រូវបានធានារ៉ាប់រងមានកំហុស ហើយសាមីខ្លួនព្រមទទួលស្គាល់កំហុសនោះ រាល់ការទាមទារទាំងឡាយរបស់អ្នកត្រូវបានធានារ៉ាប់រងដែលមានចែងក្នុងលក្ខខណ្ឌទូទៅនៃបណ្ណសន្យារ៉ាប់រង នឹងត្រូវចាត់ទុកជាអសារបង់ ។

### មាត្រា ៩២.-

ក្នុងករណីដែលគ្មានការសះជានឹងគ្នា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ជូនកំណត់ហេតុនៃការមិនសះជាទៅកាន់វេទិកាមជ្ឈត្តកម្ម ឬប្ដឹងទៅតុលាការមានសមត្ថកិច្ច ។ អាជ្ញាយុកាលនៃបណ្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬបណ្ដឹងទៅតុលាការមានសមត្ថកិច្ចមានរយៈពេល ៩០(កៅសិប)ថ្ងៃ គិតពីថ្ងៃដែលភាគីពុំបានសះជានឹងគ្នា បើពុំនោះទេ សិទ្ធិប្ដឹងនោះ នឹងត្រូវបាត់បង់ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្មឬតុលាការមានសមត្ថកិច្ចត្រូវបានរលត់ដោយស្វ័យប្រវត្តិ ក្នុងករណីមានការព្រមព្រៀងសះជានឹងគ្នារវាងគូភាគី និងមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការសះជានោះ ។

## មាត្រា ៩៣.–

នីតិវិធីនៃការផ្សះផ្សាវិវាទត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ១០
# ទណ្ឌកម្មខាងវិន័យ

## មាត្រា ៩៤.–

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចដាក់ទណ្ឌកម្មខាងវិន័យចំពោះក្រុមហ៊ុនធានារ៉ាប់រងណាមួយ ប្រសិនបើក្រុមហ៊ុននោះបង្កសកម្មភាពដូចខាងក្រោម៖

ក- ក្រុមហ៊ុនធានារ៉ាប់រងធ្វើប្រតិបត្តិការអាជីវកម្ម ដែលធ្វើឲ្យខូចប្រយោជន៍ដល់អ្នកត្រូវបានធានារ៉ាប់រង ម្ចាស់បំណុល ឬសាធារណជន ។

ខ- ក្រុមហ៊ុនធានារ៉ាប់រងបង្កើនចំណាយរបស់ខ្លួនខ្ពស់ហួសហេតុ ធៀបនឹងចំណូលបុព្វលាភដែលទទួលបាន ។

គ- ក្រុមហ៊ុនធានារ៉ាប់រងមិនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មក្នុងរយៈពេល ០៦(ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណ ។

ឃ- ក្រុមហ៊ុនធានារ៉ាប់រងប្រព្រឹត្តល្មើស នឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធ នឹងវិស័យធានារ៉ាប់រង ។

## មាត្រា ៩៥.–

ទណ្ឌកម្មខាងវិន័យមានដូចខាងក្រោម៖

ក- បញ្ឈប់ការលក់បណ្ណសន្យារ៉ាប់រងថ្មី ។

ខ- បញ្ឈប់ការអនុញ្ញាតសកម្មភាពអាជីវកម្មធានារ៉ាប់រងថ្មីឬការទិញលក់ផ្សេងៗ ។

គ- បញ្ឈប់សកម្មភាពផ្សេងៗរបស់ក្រុមហ៊ុនធានារ៉ាប់រង ប្រសិនបើយល់ឃើញថាស្ថានភាពហិរញ្ញវត្ថុមិនមានភាពរឹងមាំ ។

ឃ- ដាក់កំហិតលើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។

ង- ផ្ទេរបណ្ណសន្យារ៉ាប់រងដែលមិនទាន់ផុតកំណត់មួយផ្នែក ឬទាំងស្រុងរបស់ក្រុមហ៊ុន ។

ច- បញ្ឈប់មុខងាររបស់នាយកនិងអ្នកគ្រប់គ្រង ។

ឆ- ដកហូតអាជ្ញាបណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុន ។

**មាត្រា ៩៦.–**

នីតិវិធីនិងកម្រិតនៃការដាក់ទណ្ឌកម្មខាងវិន័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៩៧.–**

បុគ្គលជាម្ចាស់យានយន្តដែលមិនមានការធានារ៉ាប់រងជាកាតព្វកិច្ចស្របតាមមាត្រា ៣៣ និងមាត្រា ៣៤ នៃច្បាប់នេះ ហើយដែលយានយន្តត្រូវបានយកទៅធ្វើចរាចរណ៍នៅលើផ្លូវថ្នល់សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥ ០០០(ដប់ប្រាំពាន់)រៀល ទៅ ១ ៥០០ ០០០ (មួយលានប្រាំសែន)រៀល និងតម្រូវឲ្យមានការធានារ៉ាប់រង ។

បុគ្គលដែលជាម្ចាស់ការដ្ឋាន ហើយបានបើកការដ្ឋានដោយមិនមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានស្របតាមមាត្រា ៣៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ៥០០ ០០០ (មួយលានប្រាំសែន)រៀល ទៅ ១៥០ ០០០ ០០០(មួយរយហាសិបលាន)រៀល និងតម្រូវឲ្យមានការធានារ៉ាប់រង ។

បុគ្គលដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូននានា ហើយមិនមានការធានារ៉ាប់រងភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបាយដឹកជញ្ជូនស្របតាមមាត្រា ៣៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ៥០០ ០០០ (មួយលានប្រាំសែន) រៀល ទៅ ១៥០ ០០០ ០០០(មួយរយហាសិបលាន)រៀល និងតម្រូវឲ្យមានការធានារ៉ាប់រង ។

**មាត្រា ៩៨.–**

បុគ្គលដែលប្រគល់អំណាចដឹកនាំ ចាត់ចែង និងទូទាត់ឲ្យដល់បុគ្គលណាដែលធ្លាប់ត្រូវបានផ្តន្ទាទោសចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ចំពោះបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន)រៀល និងត្រូវដកហូតអាជ្ញាបណ្ណធានារ៉ាប់រង ។

**មាត្រា ៩៩.–**

បុគ្គលដែលធ្វើអាជីវកម្មធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់ ។

ក្នុងករណីមិនរាងចាល បុគ្គលនោះត្រូវផ្តន្ទាទោសដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ ២០០ ០០០ ០០០ (ពីររយលាន) រៀល
- ចំពោះនីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៤០០ ០០០ ០០០(បួនរយលាន)រៀល និងមិនអនុញ្ញាតឲ្យធ្វើអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលកំណត់ណាមួយ ។

## មាត្រា ១០០.-

អភិបាល នាយក អ្នកគ្រប់គ្រងគ្រឹះស្ថានធានារ៉ាប់រង អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត ឬប្រព្រឹត្តអំពើរំលោភអំណាចក្នុងការបំពេញមុខងាររបស់ខ្លួនក្នុងគោលបំណងទទួលផលប្រយោជន៍ផ្ទាល់ខ្លួន ឬដល់តតិយជន ឬក្នុងគោលបំណងធ្វើឲ្យខូចខាតដល់គ្រឹះស្ថានធានារ៉ាប់រង ហើយបណ្តាលឲ្យមានការខូចខាតដល់ទ្រព្យសម្បត្តិរបស់គ្រឹះស្ថានធានារ៉ាប់រងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២(ពីរ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន)រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន)រៀល ។

## មាត្រា ១០១.-

អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលរារាំង ឬជ្រៀតជ្រែកដល់មន្ត្រីអធិការកិច្ចធានារ៉ាប់រងក្នុងការបំពេញមុខងារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២(ពីរ)ឆ្នាំទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀលទៅ ១០ ០០០ ០០០ (ដប់លាន)រៀល ។

## មាត្រា ១០២.-

បុគ្គលដែលប្រព្រឹត្តបទឆបោកក្នុងវិស័យធានារ៉ាប់រង ត្រូវផ្តន្ទាទោសដោយយោងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

## មាត្រា ១០៣.-

បុគ្គលដែលធ្វើអាជីវកម្មធានារ៉ាប់រងដែលបានក្លែងបន្លំឯកសារ ឬផ្សព្វផ្សាយ ឬផ្តល់ព័ត៌មានមិនពិតដែលនាំឲ្យខូចប្រយោជន៍ដល់សាធារណជន ឬបំភ័ន្តអាជ្ញាធរពាក់ព័ន្ធ ត្រូវផ្តន្ទាទោសដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ)ឆ្នាំទៅ ០៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ១៥០ ០០០ ០០០ (មួយរយ ហាសិបលាន)រៀល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ចំពោះនីតិបុគ្គលត្រូវផ្តន្ទាទោសដាក់ពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ ៣០០ ០០០ ០០០ (បីរយលាន)រៀល ។

**មាត្រា ១០៤.–**

បុគ្គលដែលធ្វើអាជីវកម្មជានាវ៉ាប់រង ដែលបានបំផ្លាញភស្តុតាងនៃបទល្មើសក្នុងវិស័យជានាវ៉ាប់រង ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្រាវជ្រាវរបស់មន្ត្រីអធិការកិច្ច ឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ត្រូវផ្តន្ទាទោសដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ) ឆ្នាំទៅ ០៣(បី) ឆ្នាំនិងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន)រៀលទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល
- ចំពោះនីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៤០០ ០០០ ០០០(បួនរយលាន)រៀល ។

**មាត្រា ១០៥.–**

បុគ្គលធ្វើអាជីវកម្មជានាវ៉ាប់រង ដែលប្រព្រឹត្តបទល្មើសទាក់ទងនឹងបទសម្អាតប្រាក់ ត្រូវផ្តន្ទាទោសដោយបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១០៦.–**

បុគ្គលធ្វើអាជីវកម្មជានាវ៉ាប់រង ដែលទម្លាយការសម្ងាត់វិជ្ជាជីវៈជានាវ៉ាប់រងដែលកំណត់ដោយគ្រឹះស្ថានជានាវ៉ាប់រងហើយបណ្តាលឲ្យខូចប្រយោជន៍ដល់គ្រឹះស្ថានជានាវ៉ាប់រងនោះ ត្រូវផ្តន្ទាទោសដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ទៅ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន)រៀល
- ចំពោះនីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៤០០ ០០០ ០០០ (បួនរយលាន)រៀល ។

**មាត្រា ១០៧.–**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០០ មាត្រា ១០១ មាត្រា ១០៣ មាត្រា ១០៤ និងមាត្រា ១០៦ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

ចំពោះនីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០៣ មាត្រា ១០៤ និងមាត្រា ១០៦ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០៨.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចកំណត់និងធ្វើការពិន័យអន្តរការណ៍ចំពោះគ្រឹះស្ថានធានារ៉ាប់រងទាំងឡាយដែលមិនគោរពតាមការណែនាំរបស់ក្រសួង ។

បែបបទ និងនីតិវិធីនៃការធ្វើពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១០៩.-**

ចំពោះបទល្មើសទាំងឡាយណាដែលពុំមានកំណត់នៅក្នុងច្បាប់នេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ១២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១១០.-**

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់រងចំពោះហានិភ័យទាំងឡាយ ទោះជាប្រភេទធានារ៉ាប់រងអាយុជីវិតក្តី ឬជាប្រភេទធានារ៉ាប់រងទូទៅក្តី អាចជាការចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងក្រៅស្រុក ។ ប្រភេទកិច្ចសន្យាធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១១១.-**

ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត មិនអនុវត្តចំពោះការខូចខាតបណ្តាលមកពីគ្រោះថ្នាក់ដែលកើតឡើងនៅក្រៅភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែមានកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីផ្សេងពីនេះ ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ១១២.-**

អាជ្ញាបណ្ណធានារ៉ាប់រងដែលបានផ្តល់ជូនគ្រឹះស្ថានធានារ៉ាប់រងទាំងអស់ អនុលោមតាមច្បាប់ស្តីពីធានារ៉ាប់រងដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០០ នៅបន្តសុពលភាពរហូតដល់ផុតកាលកំណត់នៃអាជ្ញាបណ្ណ ទោះបីជាច្បាប់នេះចាប់ផ្តើមអនុវត្តក៏ដោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងរយៈពេល ០៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទអនុវត្តច្បាប់នេះ ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយដែលបាន និងកំពុងប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញដើមទុនអប្បបរមាឲ្យបានគ្រប់ចំនួន ដូចមានចែងក្នុងមាត្រា ៤៤ នៃច្បាប់នេះ។

## ជំពូកទី១៤
## អវសានប្បញ្ញត្តិ

**មាត្រា ១១៣ .-**

ច្បាប់ស្តីពីការធានារ៉ាប់រងដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០០ ត្រូវបាត់បង់អានុភាពអនុវត្តចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត លើកលែងតែករណីដែលមានចែងក្នុងមាត្រា ១១២ នៃជំពូកទី ១៣ ស្តីពីអន្តរប្បញ្ញត្តិនៃច្បាប់នេះ។

បទដ្ឋានគតិយុត្តក្រោមច្បាប់ទាក់ទង នឹងច្បាប់ស្តីពីការធានារ៉ាប់រងដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ត្រូវបន្តអានុភាពអនុវត្ត រហូតមានបទដ្ឋានថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយ នឹងស្មារតីនៃច្បាប់នេះ។

ច្បាប់នេះត្រូវអនុវត្តក្រោយរយៈពេល ០៦(ប្រាំមួយ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

**មាត្រា ១១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧-១៤០៨.១០២៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ ១០២៣ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**